


សង្ខេបគោលនយោបាយលេខ៖ ១៤

# ការវាយតម្លៃអំពីស្ថានភាព និងតម្រូវការជាក់ស្តែងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់អនុវត្តការងារក្នុងប្រព័ន្ធគាំពារសង្គម

## ១. សារបាន

រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញ និងកំពុងពង្រីកវិសាលភាពប្រព័ន្ធគាំពារសង្គម ដើម្បីផ្តល់ការគាំពារ ដល់ប្រជាពលរដ្ឋ ដោយឈរលើអភិក្រម «ពង្រឹងប្រព័ន្ធ ដើម្បីពង្រីកការគ្របដណ្តប់»។ ជារួម ប្រព័ន្ធគាំពារសង្គមកម្ពុជាត្រូវបានពង្រីកវិសាលភាពធំជាងមុន ដែលទាមទារឱ្យមានការបន្តចូលរួមសហការ និងកិច្ចខិតខំរួមគ្នាពីសំណាក់គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ក្នុងការអនុវត្តការងារក្នុងប្រព័ន្ធគាំពារសង្គម, រដ្ឋបាលថ្នាក់ក្រោមជាតិជាតួអង្គជួរមុខអនុវត្តការងារ និងមានទំនាក់ទំនងជាមួយប្រជាពលរដ្ឋផ្ទាល់នៅមូលដ្ឋាន។ ដោយមើលឃើញពីតួនាទីដ៏សំខាន់របស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងប្រព័ន្ធគាំពារសង្គម, អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម ដោយមានការគាំទ្រពីទីភ្នាក់ងារអាល្លឺម៉ង់សម្រាប់កិច្ចសហប្រតិបត្តិការបច្ចេកទេស (GIZ) បានសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ធ្វើការសិក្សាវាយតម្លៃអំពីតម្រូវការ និងបញ្ហាប្រឈមនានា ដែលរដ្ឋបាលថ្នាក់ក្រោមជាតិបាន និងកំពុងជួបប្រទះ ដើម្បីផ្តល់ជាភស្តុតាង និងមូលដ្ឋានក្នុងការត្រៀមលក្ខណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីឆ្លើយតបនឹងការពង្រីកវិសាលភាពនៃកម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គមនានាតាមរយៈការលើកកម្ពស់ការយល់ដឹង និងការដោះស្រាយបញ្ហាប្រឈមនាពេលបច្ចុប្បន្ន, ការជំរុញកិច្ចសហប្រតិបត្តិការរវាងរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់កម្រិត, និងការធានានូវអំណាចផ្លូវច្បាប់ របស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ដើម្បីបំពេញការងាររបស់ខ្លួនក្នុងប្រព័ន្ធគាំពារសង្គមយ៉ាងរលូន និងប្រកបដោយប្រសិទ្ធភាព។

រៀបចំដោយក្រុមប្រឹក្សាជាតិគាំពារសង្គម

ខែតុលា ឆ្នាំ២០២៥

## ២. គោលបំណង និងវិធីសាស្ត្រនៃការសិក្សាវាយតម្លៃ

ការសិក្សាវាយតម្លៃអំពីស្ថានភាព និងតម្រូវការជាក់ស្តែងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ សម្រាប់អនុវត្តការងារក្នុងប្រព័ន្ធគាំពារសង្គម បានចាប់ផ្តើមតាំងពីពាក់កណ្តាលឆ្នាំ២០២៣ រហូតដល់ខែមករា ឆ្នាំ២០២៤ ក្នុងគោលបំណងកំណត់អំពីតម្រូវការ និងបញ្ហាប្រឈម ដែលរដ្ឋបាលថ្នាក់ក្រោមជាតិបាន និងកំពុងជួបប្រទះមានដូចជា៖ **គម្លាត ឬកង្វះខាតនៃការយល់ដឹងផ្នែកគាំពារសង្គម, កម្រិតនៃការចូលរួម និងការគាំទ្រពីថ្នាក់ជាតិទៅថ្នាក់ក្រោមជាតិ ក្នុងការអនុវត្តការងារក្នុងប្រព័ន្ធគាំពារសង្គម, តម្រូវការធនធានចាំបាច់នានាសម្រាប់អនុវត្តការងារ និងកង្វះខាតនៃក្របខណ្ឌគតិយុត្តផ្សេងៗ**។ ការសិក្សាវាយតម្លៃបានប្រើប្រាស់វិធីសាស្ត្រគុណវិស័យ ដោយធ្វើការប្រមូលទិន្នន័យ និងព័ត៌មាននៅតាមបណ្តារាជធានី-ខេត្តចំនួន ៨ ដែលមានអ្នកចូលរួមសរុបចំនួន **៥៣៥ នាក់** (**ស្រីចំនួន ២២៩នាក់**)។

## ៣. លទ្ធផលនៃការសិក្សា

### ៣.១. ក្របខណ្ឌគតិយុត្ត

ការសិក្សាបានបង្ហាញថា ក្របខណ្ឌគតិយុត្តដែលមានស្រាប់ មានភាពគ្រប់គ្រាន់ ប៉ុន្តែការយល់ដឹងរបស់មន្ត្រីអនុវត្តកម្មវិធី ហាក់នៅមានកម្រិត។ ព្រមជាមួយគ្នានេះ កង្វះការរៀបចំរចនាសម្ព័ន្ធស្ថាប័នក្នុងការអនុវត្តការងារក្នុងប្រព័ន្ធគាំពារសង្គមនៅរដ្ឋបាលថ្នាក់ក្រោមជាតិមិនទាន់មានភាពល្អប្រសើរ នាំឱ្យមិនមានការប្រគល់មុខងារភារកិច្ចក្នុងប្រព័ន្ធគាំពារសង្គមជាផ្លូវការនៅមានកម្រិត ជាហេតុធ្វើឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិយល់ថា ការងារនានាក្នុងប្រព័ន្ធគាំពារសង្គម ជាបន្ទុកការងារបន្ថែម និងជាការងារបែបមួយគ្រាៗ។

**រូបភាពទី១៖ ការយល់ឃើញរបស់រដ្ឋបាលថ្នាក់ក្រោមជាតិទាក់ទងនឹងលទ្ធភាពអាចរកបាននូវឯកសារណែនាំស្តីពីការអនុវត្តការងារក្នុងប្រព័ន្ធគាំពារសង្គម**



ទន្ទឹមនេះ លទ្ធភាពអាចស្វែងរកបាននូវឯកសារណែនាំស្តីពីការអនុវត្តការងារក្នុងប្រព័ន្ធគាំពារសង្គម កម្មវិធីជាតិជំនួយសង្គម និងរបបសន្តិសុខសង្គមមួយចំនួន, មគ្គុទេសក៍បច្ចេកទេសតាមវិស័យ ក៏ដូចជាសេចក្តីណែនាំពាក់ព័ន្ធនឹងការបែងចែកថវិកាសម្រាប់អនុវត្ត នៅមានកម្រិត ដែលមិនទាន់អាចសម្រួលដល់ការអនុវត្ត និងការទាញយកមកប្រើប្រាស់បានតាមតម្រូវការនៅឡើយ។ តាមរយៈរូបភាពទី១, ការវាយតម្លៃបានបង្ហាញថា ៦៣% នៃអ្នកចូលរួមការសិក្សានៅថ្នាក់រាជធានី-ខេត្ត និង៣៣% នៅថ្នាក់ក្រុង-ស្រុក-ខណ្ឌ ទទួលបានគោលការណ៍ណែនាំពាក់ព័ន្ធនឹងប្រព័ន្ធគាំពារសង្គមពីកម្រិតក្រសួង ខណៈដែលអ្នកចូលរួមថ្នាក់រាជធានី-ខេត្ត និងក្រុង-ស្រុក-ខណ្ឌមានប្រមាណ១០% ឬទាបជាងនេះ បានបញ្ជាក់ថាពួកគេអនុវត្តដោយពឹងផ្អែកលើអនុក្រឹត្យ និងប្រកាសនានា។ ក្រៅពីនេះ សេចក្តីណែនាំពាក់ព័ន្ធនឹងការតាមដាន និងវាយតម្លៃ ក៏ពុំទាន់ត្រូវបានរៀបចំផងដែរ។

ការផ្សព្វផ្សាយអំពីប្រព័ន្ធគាំពារសង្គម និងនីតិវិធីអនុវត្តកម្មវិធីជាតិជំនួយសង្គម និងរបបសន្តិសុខសង្គមនានា នៅមិនទាន់បានទូលំទូលាយ ហើយចំនួនវគ្គបណ្តុះបណ្តាលនៅមានកម្រិតរួមជាមួយវិធីសាស្ត្របង្រៀន និងសម្ភារៈឧបទេសសម្រាប់បង្រៀន មិនទាន់សមស្រប ក៏ដូចជាកង្វះខាតសម្ភារៈផ្សព្វផ្សាយ។

## ៣.២. ធនធានមនុស្ស និងធនធានហិរញ្ញវត្ថុ

កង្វះធនធានមនុស្ស និងធនធានហិរញ្ញវត្ថុត្រូវបានរកឃើញថា ជាបញ្ហាប្រឈមដ៏ចម្បងចំពោះការអនុវត្តកម្មវិធីជាតិជំនួយសង្គម និងរបបសន្តិសុខសង្គម។ ការធ្វើប្រតិភូកម្មតួនាទីភារកិច្ចដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយយោងតាមការរៀបចំរដ្ឋបាល និងហិរញ្ញវត្ថុថ្មីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវការពេលវេលាសមស្របមួយជាពិសេស ថ្នាក់ក្រុង-ស្រុក-ខណ្ឌ។ អន្តរកាលនៃការរៀបចំ និងសម្របខ្លួននេះ គឺត្រូវការពេលវេលាច្រើន ដែលអំឡុងពេលនេះ គួរយកចិត្តទុកដាក់គាំទ្រដល់ការអនុវត្តការងារក្នុងប្រព័ន្ធគាំពារសង្គម នៅថ្នាក់ឃុំ-សង្កាត់។ ទន្ទឹមនឹងនេះ, ការវិភាជថវិកាបន្ថែមសម្រាប់អនុវត្តមុខងារថ្មីៗ រួមទាំងការងារក្នុងប្រព័ន្ធគាំពារសង្គម ក៏មិនទាន់មានភាពច្បាស់លាស់ ផងដែរ។

ពាក់ព័ន្ធនឹងធនធានមនុស្ស, ការសិក្សាបានបង្ហាញថា ការយល់ដឹងរបស់ភាគីពាក់ព័ន្ធលើការងារក្នុងប្រព័ន្ធ-គាំពារសង្គមនៅមានកម្រិតនៃការយល់ដឹងផ្សេងៗគ្នា។ រដ្ឋបាលថ្នាក់ក្រោមជាតិយល់ឃើញថា ការងារក្នុងប្រព័ន្ធគាំពារសង្គមជាសកម្មភាពសប្បុរសធម៌ ដែលមិនមែនជាផ្នែកនៃកាតព្វកិច្ចការងាររបស់ពួកគេឡើយ និងជាបន្ទុកបន្ថែម ដែលមិនទាន់មានលក្ខណៈជាប្រព័ន្ធ និងមិនមានរចនាសម្ព័ន្ធច្បាស់លាស់ក្នុងការអនុវត្ត។ ការធ្វើការងារលើសម៉ោង, ពេលមិនគ្រប់គ្រាន់ និងមន្ត្រីវ័យចាស់ គឺជាបញ្ហាប្រឈមក្នុងការអនុវត្តការងារ។ លើសពីនេះ កង្វះបុគ្គលិកបច្ចេកទេស, កង្វះគោលការណ៍លើកទឹកចិត្ត, បញ្ហាសេវាអ៊ីនធឺណិត, កង្វះមធ្យោបាយធ្វើដំណើរ និងឧបករណ៍បច្ចេកវិទ្យាចាស់ហួសសម័យ ក៏ជាបញ្ហាប្រឈម ផងដែរ។ រូបភាពទី២ បានបង្ហាញពីកត្តាមួយចំនួនដែលជាបញ្ហាប្រឈមរបស់រដ្ឋបាលថ្នាក់ឃុំ-សង្កាត់ក្នុងការអនុវត្តការងារក្នុងប្រព័ន្ធគាំពារសង្គម រួមមាន៖ សមត្ថភាពមន្ត្រីឃុំ-សង្កាត់នៅមានកម្រិត និងកង្វះវគ្គបណ្តុះបណ្តាល (១៩%), ការចូលរួមតិចតួចពីថ្នាក់ឃុំ-សង្កាត់ (១៥%), និងកង្វះបទពិសោធលើការងារគាំពារសង្គម (១០%)។

### រូបភាពទី២៖ បញ្ហាប្រឈមរបស់រដ្ឋបាលថ្នាក់ឃុំ-សង្កាត់ក្នុងការអនុវត្តការងារក្នុងប្រព័ន្ធគាំពារសង្គម




រីឯធនធានហិរញ្ញវត្ថុវិញ, បញ្ហាប្រឈមសំខាន់ៗដែលរដ្ឋបាលថ្នាក់ក្រោមជាតិកំពុងជួបប្រទះ មានដូចជា៖ ភាពយឺតយ៉ាវនៃការទម្លាក់ថវិកា, ភាពមិនច្បាស់លាស់នៃការវិភាជថវិកា និងភាពស្មុគស្មាញនៃឯកសារទូទាត់។ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវការការណែនាំបន្ថែមលើការបែងចែកថវិកាសម្រាប់អនុវត្តការងារក្នុងប្រព័ន្ធគាំពារសង្គម ដោយហេតុថា បច្ចុប្បន្ន ការបែងចែងថវិកាសម្រាប់អនុវត្តនៅថ្នាក់ក្រោមជាតិ ផ្អែកជាចម្បងលើសេចក្តីណែនាំទូទៅពីរដ្ឋបាលថ្នាក់ជាតិ ដែលពុំបានចង្អុលបង្ហាញពីវិធីសាស្ត្របែងចែកថវិកាជាក់លាក់ ស្របតាមលក្ខណៈ និងតម្រូវការអនុវត្តការងារជាក់ស្តែងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិឡើយ។

## ៣.៣. ការគាំទ្រដែលផ្តល់ជូនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ

ទោះបីជាការយល់ឃើញរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំពោះការគាំទ្រដែលទទួលបាន មានភាពវិជ្ជមានក្តី ក៏ការគាំទ្រនេះ នៅពុំទាន់គ្រប់គ្រាន់តាមតម្រូវការនៅឡើយ។ រដ្ឋបាលរាជធានី-ខេត្ត ត្រូវបានកត់សម្គាល់ឃើញថាមានភាពសកម្មភាគច្រើនលើការកសាងសមត្ថភាព ដូចជា ការផ្តល់ការបណ្តុះបណ្តាល និងសិក្ខាសាលា, ការសម្របសម្រួលការអនុវត្ត, និងការផ្សព្វផ្សាយ។ យ៉ាងណាមិញ រដ្ឋបាលក្រុង-ស្រុក-ខណ្ឌ បានបង្ហាញពីកង្វះការគាំទ្រមានដូចជា៖ ផ្នែកសម្ភារៈ ថវិកា និងឯកសារផ្សព្វផ្សាយ។ ទន្ទឹមនឹងនេះ រដ្ឋបាលឃុំ-សង្កាត់ ដែលជាអ្នកអនុវត្តផ្ទាល់ជាមួយពលរដ្ឋជាក្រុមគោលដៅនៅមូលដ្ឋាន បានបង្ហាញតម្រូវការខ្ពស់ក្នុងការកសាងសមត្ថភាព តាមរយៈការបណ្តុះបណ្តាល ដែលគួរមានជាបន្តបន្ទាប់។ រូបភាពទី៣ បង្ហាញថា ការគាំទ្រដែលថ្នាក់ឃុំ-សង្កាត់ត្រូវការពីថ្នាក់ក្រុង-ស្រុក-ខណ្ឌ និងរាជធានី-ខេត្ត ផ្តោតសំខាន់លើការរៀបចំសិក្ខាសាលាអប់រំផ្សព្វផ្សាយ និងការបណ្តុះបណ្តាលបន្ថែម (៥៩%) និងការផ្តល់ប្រាក់លើកទឹកចិត្ត (៣៥%)។

**រូបភាពទី៣៖ តម្រូវការនៃការគាំទ្រពីថ្នាក់ក្រុង-ស្រុក-ខណ្ឌ សម្រាប់ថ្នាក់ឃុំ-សង្កាត់**




ក្រៅពីនេះ បច្ចុប្បន្ន ប្រព័ន្ធទិន្នន័យអ្នកទទួលផលស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ជាតិ ដូច្នេះ រដ្ឋបាលថ្នាក់ក្រោមជាតិ បាននិងកំពុងជួបប្រទះនូវការលំបាកក្នុងការគ្រប់គ្រង និងក្តាប់បានព័ត៌មានរបស់អ្នកទទួលផល សម្រាប់ចូលរួមដោះស្រាយបញ្ហាពាក់ព័ន្ធនឹងទិន្នន័យរបស់អ្នកទទួលផលបានទាន់ពេល។

## ៣.៤. បញ្ហាប្រឈមក្នុងការអនុវត្តការងារពាក់ព័ន្ធនឹងប្រព័ន្ធគាំពារសង្គម

ជារួម បញ្ហាប្រឈមសំខាន់ៗសម្រាប់រដ្ឋបាលរាជធានី-ខេត្ត ក្រុង-ស្រុក-ខណ្ឌ និងឃុំ-សង្កាត់ រួមមាន៖ កង្វះការគាំទ្រផ្នែកហិរញ្ញវត្ថុ, កង្វះធនធានមនុស្ស, ចំណេះដឹងបច្ចេកទេសនៅមានកម្រិត, កង្វះសម្ភារៈបច្ចេកទេស និងសម្ភារៈការិយាល័យ, និងកង្វះខាតការសម្របសម្រួល។ ចំពោះភាពជាដៃគូ និងកិច្ចសហការក្នុងការអនុវត្តការងារពាក់ព័ន្ធនឹងប្រព័ន្ធគាំពារសង្គមនៅរាជធានី-ខេត្ត និងក្រុង-ស្រុក-ខណ្ឌ បាន និងកំពុងក្លាយជាបញ្ហាប្រឈម ដោយហេតុថារចនាសម្ព័ន្ធស្ថាប័ន និងការកំណត់តួនាទីភារកិច្ច ដើម្បីអនុវត្តការងារពាក់ព័ន្ធនឹងប្រព័ន្ធគាំពារសង្គមសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ មិនទាន់មានភាពច្បាស់លាស់នៅឡើយ។ ព្រមជាមួយគ្នានេះ កង្វះឧបករណ៍ និងសម្ភារៈផ្សព្វផ្សាយអំពីគោលនយោបាយ កម្មវិធីជាតិជំនួយសង្គម និងរបបសន្តិសុខសង្គមនានា ក៏ជាឧបសគ្គសំខាន់មួយសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់កម្រិតដែលបាន និងកំពុងបង្កការរាំងស្ទះដល់ប្រសិទ្ធភាពនៃការអនុវត្ត។

បន្ថែមពីនេះ កត្តាខាងក្រៅមួយចំនួនទៀតដូចជា ការចូលរួមពីសហគមន៍នៅមានកម្រិត, ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីប្រព័ន្ធគាំពារសង្គមក៏នៅមានកម្រិត និងចលនាបម្លាស់ទីរបស់ប្រជាពលរដ្ឋញឹកញាប់ ក៏រួមចំណែកបង្កជាបញ្ហាប្រឈម ផងដែរ។

## ៧. អនុសាសន៍គន្លឹះ

ផ្អែកលើមូលដ្ឋាននៃលទ្ធផលខាងលើ, ការវាយតម្លៃនេះបានលើកជាអនុសាសន៍គន្លឹះមួយចំនួន ដើម្បីចូលរួមឆ្លើយតបនឹងស្ថានភាពបច្ចុប្បន្ន និងដើម្បីជំរុញឱ្យប្រព័ន្ធគាំពារសង្គមកាន់តែមានភាពធន់ និងបរិយាបន្ន ដែលបន្សុីគ្នាទៅតាមតម្រូវការ និងទស្សនៈរបស់ភាគីពាក់ព័ន្ធនានា ដូចខាងក្រោម៖

### ១. ការធ្វើឱ្យប្រសើរឡើងនូវក្របខណ្ឌគតិយុត្ត៖

- **ក្របខណ្ឌគតិយុត្តដែលណែនាំពីការរៀបចំរចនាសម្ព័ន្ធការងារនៅរដ្ឋបាលក្រោមជាតិ និងការប្រើប្រាស់ថវិកា សម្រាប់ការងារក្នុងប្រព័ន្ធគាំពារសង្គម៖** គួររៀបចំប្រកាស ឬសេចក្តីណែនាំស្តីពីការរៀបចំរចនាសម្ព័ន្ធ និងកំណត់តួនាទីរដ្ឋបាលថ្នាក់ក្រោមជាតិទៅតាមកម្រិតនីមួយៗ ដើម្បីបែងចែកមុខងារអនុវត្តការងារក្នុងប្រព័ន្ធគាំពារសង្គមនៅរដ្ឋបាលក្រោមជាតិឱ្យបានច្បាស់លាស់។ បន្ថែមពីនេះ គួររៀបចំឱ្យមានក្របខណ្ឌគតិយុត្ត ឬគោលការណ៍ណែនាំ ដែលអនុញ្ញាតឱ្យមានការបែងចែកថវិកាប្រកបដោយភាពបត់បែនសម្រាប់ការអនុវត្តសកម្មភាពគាំទ្រការងារក្នុងប្រព័ន្ធគាំពារសង្គមនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលអនុញ្ញាតឱ្យការប្រើប្រាស់ធនធានថវិកាស្របតាមតម្រូវការចាំបាច់ និងបរិបទនៃរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់កម្រិត និងទៅតាមលក្ខខណ្ឌសង្គម-សេដ្ឋកិច្ច។

- **សៀវភៅមគ្គុទ្ទេសក៍ណែនាំរួម៖** គួររៀបចំសៀវភៅមគ្គុទ្ទេសក៍រួមមួយ ដែលរួមបញ្ចូលគោលការណ៍ណែនាំទាំងឡាយ សម្រាប់ការអនុវត្តកម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គមនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយផ្តោតការយកចិត្តទុកដាក់លើខ្លឹមសារឱ្យមានភាពសាមញ្ញ និងងាយយល់សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសរដ្ឋបាលឃុំ-សង្កាត់។ សៀវភៅមគ្គុទេសក៍ណែនាំរួមនេះក៏គួរដាក់ឱ្យងាយស្រួលទាញយកមកប្រើប្រាស់តាមប្រព័ន្ធអនឡាញ ផងដែរ។

- **មគ្គុទ្ទេសក៍បច្ចេកទេសតាមវិស័យជាក់លាក់ និងមគ្គុទ្ទេសក៍អំពីការតាមដាន និងវាយតម្លៃ៖** គួររៀបចំគោលការណ៍ណែនាំបច្ចេកទេសទៅតាមវិស័យនីមួយៗ ដើម្បីធ្វើការណែនាំលើការអនុវត្តការងារក្នុងវិស័យនីមួយៗមានប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់។ ទន្ទឹមនេះ ក៏គួររៀបចំមគ្គុទ្ទេសក៍ណែនាំសម្រាប់ការត្រួតពិនិត្យ តាមដាន និងវាយតម្លៃ ដែលមានលក្ខណៈជាប្រព័ន្ធសម្រាប់ការងារគាំពារសង្គមនៅថ្នាក់ក្រោមជាតិ ដើម្បីបង្កើនប្រសិទ្ធភាព នៃការត្រួតពិនិត្យ និងគាំទ្រសកម្មភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយអនុលោមតាមក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម។ មគ្គុទ្ទេសក៍ទាំងនេះ ត្រូវមានភាពងាយយល់ និងសាមញ្ញ ជាពិសេសសម្រាប់រដ្ឋបាលឃុំ-សង្កាត់ ដោយផ្តោតសំខាន់លើតួនាទីរបស់រដ្ឋបាលក្រុង-ស្រុក-ខណ្ឌ និងឃុំ-សង្កាត់ សំដៅធានាបាននូវការតាមដាន ការអនុវត្តការងារ និងដោះស្រាយបញ្ហាពាក់ព័ន្ធនឹងការងារក្នុងកម្មវិធីជាតិជំនួយសង្គម និងរបបសន្តិសុខសង្គម បានទាន់ពេលវេលា។ ឯកសារទាំងនេះ គួររក្សាទុកក្នុងប្រព័ន្ធទិន្នន័យកណ្តាលណាមួយ សម្រាប់ងាយស្រួលទាញយកមកប្រើប្រាស់។

- **ការឆ្លើយតបនឹងសំណូមពរ និងមតិកែលម្អរបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងអង្គការមិនមែនរដ្ឋាភិបាល៖** គួរជំរុញឱ្យមានការចូលរួមយ៉ាងសកម្មពីក្រសួង-ស្ថាប័នពាក់ព័ន្ធ និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីផ្តល់មតិកែលម្អ និងយោបល់នានាទាក់ទងនឹងក្របខណ្ឌគតិយុត្ត ដែលមានស្រាប់ និងជំរុញកិច្ចសហការបន្ថែម។
- **ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអង្គការសង្គមស៊ីវិល៖** គួរពង្រឹងកិច្ចសហការជាមួយអង្គការសង្គមស៊ីវិល ដើម្បីទទួលបាននូវជំនាញ ធនធាន និងបណ្តាញសហគមន៍សម្រាប់ការអនុវត្តកម្មវិធី និងអភិបាលកិច្ច កាន់តែមានប្រសិទ្ធភាព។

## ២. ការគិតគូរបន្ថែមលើការគាំទ្រធនធានមនុស្ស និងធនធានហិរញ្ញវត្ថុ៖

- **ផ្តួចផ្តើមការពង្រឹងសមត្ថភាព៖** គួរផ្តល់អាទិភាពដល់គំនិតផ្តួចផ្តើមលើការពង្រឹងសមត្ថភាពឱ្យបានទូលំទូលាយដល់រដ្ឋបាលឃុំ-សង្កាត់ ដើម្បីបង្កើនការយល់ដឹងរបស់ពួកគាត់ទាក់ទងនឹងការងារក្នុងប្រព័ន្ធគាំពារសង្គម និងពង្រឹងជំនាញ ដែលត្រូវការសម្រាប់ការអនុវត្តកម្មវិធីប្រកបដោយប្រសិទ្ធភាព។ គំនិតផ្តួចផ្តើម ឬវិធីសាស្ត្រនៃការពង្រឹងសមត្ថភាពនេះ គួរត្រូវបានត្រួតពិនិត្យឡើងវិញជាប្រចាំ និងកែសម្រួល ស្របតាមតម្រូវការជាក់ស្តែង ផងដែរ។
- **កម្មវិធីលើកទឹកចិត្ត៖** គួរបង្កើតកម្មវិធីលើកទឹកចិត្ត ដើម្បីឆ្លើយតបទៅនឹងការធ្វើការលើសម៉ោងពេលវេលាមិនគ្រប់គ្រាន់ និងមន្ត្រីមានវ័យចំណាស់ ដើម្បីជំរុញឱ្យមានការចូលរួមខ្ពស់ និងការប្តេជ្ញាចិត្តក្នុងចំណោមអ្នកអនុវត្តការងារក្នុងប្រព័ន្ធគាំពារសង្គម។
- **ជ្រើសរើសបុគ្គលិកបច្ចេកទេស៖** គួរដោះស្រាយបញ្ហាកង្វះបុគ្គលិកបច្ចេកទេសដោយគិតគូរជ្រើសរើសបុគ្គលិក ដែលមានភាពច្នៃប្រឌិត និងផ្តល់ការលើកទឹកចិត្ត ដើម្បីទាក់ទាញអ្នកជំនាញដែលមានសមត្ថភាព។ ទន្ទឹមនេះ ក៏គួរមានឯកសារពិពណ៌នាការងារ (**ដោយមានចែងពីតួនាទី និងភារកិច្ចច្បាស់លាស់**) ដើម្បីលើកកម្ពស់នូវគណនេយ្យភាព និងការវាយតម្លៃការអនុវត្តភារកិច្ចរបស់មន្ត្រីនៅថ្នាក់ក្រុង-ស្រុក-ខណ្ឌ ដែលអាចជួយជំរុញផលិតភាពការងារ។
- **ជំរុញការផ្សព្វផ្សាយអំពីប្រព័ន្ធគាំពារសង្គម៖** គួរធ្វើយុទ្ធនាការផ្សព្វផ្សាយជាប្រចាំ និងជាបន្តបន្ទាប់អំពីទស្សនាទានពាក់ព័ន្ធនឹងប្រព័ន្ធគាំពារសង្គម, គោលការណ៍ណែនាំ, ដំណើរការ, និងអត្ថប្រយោជន៍នៃកម្មវិធីជាតិជំនួយសង្គម និងរបបសន្តិសុខសង្គម សម្រាប់អ្នកទទួលផល និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយប្រើប្រាស់យន្តការ និងសម្ភារៈដែលមានស្រាប់ និងតាមរយៈវិធីសាស្ត្រថ្មីៗ និងបង្កើនការផ្សព្វផ្សាយពីក្របខណ្ឌគតិយុត្ត ក៏ដូចជាគោលការណ៍ណែនាំតាមភាពចាំបាច់។



## ៣. ការពង្រឹងការគាំទ្រការអនុវត្តការងារក្នុងប្រព័ន្ធគាំពារសង្គមៈ

- **ប្រព័ន្ធទិន្នន័យរួមៈ** គួរបង្កើតប្រព័ន្ធទិន្នន័យរួមមួយសម្រាប់កម្មវិធីជាតិជំនួយសង្គម និងរបបសន្តិសុខសង្គម នៅកម្រិតរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលអាចជួយសម្រួលដល់ការកំណត់អត្តសញ្ញាណ, ការចុះឈ្មោះ, ការផ្ទៀងផ្ទាត់, ការផ្តល់ និងត្រួតពិនិត្យវឌ្ឍនភាព (**ប្រព័ន្ធចុះបញ្ជីអ្នកទទួលផល និងប្រព័ន្ធគ្រប់គ្រងករណី**)។
- **ការវាយតម្លៃឡើងវិញនូវឧបករណ៍ និងសម្ភារៈដែលមានៈ** គួរពិនិត្យឡើងវិញពីស្ថានភាពនៃសម្ភារៈបរិក្ខារ និងសម្ភារៈបច្ចេកទេស ដែលប្រើប្រាស់សម្រាប់ការអនុវត្តកម្មវិធីជាតិជំនួយសង្គម និងរបបសន្តិសុខសង្គម និងផ្តល់នូវជំនួយបច្ចេកទេស ឬសម្ភារៈសមស្រប ដើម្បីដោះស្រាយបញ្ហាសម្ភារៈបរិក្ខារចាស់ៗ។
- **ការជជែកពិភាក្សា និងវេទិកាសាធារណៈៈ** គួរជំរុញឱ្យមានការជជែកពិភាក្សា និងវេទិកាសាធារណៈ ស្តីពីប្រព័ន្ធគាំពារសង្គម នៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីបង្កើនប្រសិទ្ធភាពនៃការអនុវត្ត និង អត្ថប្រយោជន៍របស់អ្នកទទួលផល។